ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 08 / 2016
ម៉ោង (Time/Heure): 15 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E408/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦

ជូនចំពោះ៖ ភាគីទាំងអស់នៃសំណុំរឿង ០០២
លោក Michael G. KARNAVAS
លោក អាង ឧត្តម

ពី៖ ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

កម្មវត្ថុ៖ បញ្ហាសំខាន់ៗពាក់ព័ន្ធនឹងអ្នកជំនាញ Michael Vickery (2-TCE-94)

១. អង្គជំនុំជម្រះ សូមរំលឹកថា លោក Michael Vickery (2-TCE-94) ត្រូវបានរៀបចំឱ្យចូលមកផ្តល់សក្ខីកម្ម ក្នុងនាមជាអ្នកជំនាញនៅក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៦ (ឯកសារ E408)។ បន្ទាប់ពីការរៀបចំនេះ អង្គភាពគាំពារសាក្សី និង អ្នកជំនាញ (WESU) បានទាក់ទងទៅលោក Vickery ដែលនៅខែ មិថុនា ឆ្នាំ ២០១៦ លោកបានបញ្ជាក់ថា លោកនឹងមានវត្តមានសម្រាប់ការមកផ្តល់សក្ខីកម្ម ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ (សូមមើលឯកសារ E408/4)។

២. នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦ ក្រុមមេធាវីការពារក្តី អៀង សារី និង មាស មុត បានដាក់សំណើបន្ទាន់ជាសម្ងាត់មួយ ស្នើសុំការអនុញ្ញាតដាក់សារណាកម្រិតសក្ខីកម្មរបស់លោក Vickery (ឯកសារ E408/1)។ នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបាន

បដិសេធលើសំណើសុំនេះ។ ទោះជាបែបនេះក្តី អង្គជំនុំជម្រះបានបង្គាប់ឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ជូនដំណឹងទៅលោក Vickery ពីក្តីបារម្ភអំពីការរក្សាការសម្ងាត់ដែលក្រុមមេធាវីការពារក្តី អៀង សារី និង មាស មុត បានលើកឡើង ដើម្បីផ្តល់ឱកាសឱ្យអ្នកជំនាញជម្រាបជូនមកអង្គជំនុំជម្រះវិញថាតើស្ថានភាពនេះរារាំងលោកមិនឱ្យបញ្ចេញយោបល់ជំនាញរបស់លោកបានពេញលេញនៅក្នុងការផ្តល់សក្ខីកម្មក្នុងសំណុំរឿងនេះ ឬ យ៉ាងណា (ឯកសារ E408/2)។ នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៦ លោក Vickery បានបញ្ជាក់ដល់អង្គភាពគាំពារសាក្សី និង អ្នកជំនាញ តាមរយៈសារអេឡិចត្រូនិកម្តងទៀតពីវត្តមានរបស់លោកក្នុងការផ្តល់សក្ខីកម្ម (សូមមើល ឯកសារ E408/4)។

៣. ជាចុងក្រោយ នៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦ លោក Vickery បានជូនដំណឹងដល់អង្គភាពគាំពារសាក្សី និង អ្នកជំនាញតាមរយៈសារអេឡិចត្រូនិក ថាលោកបានសម្រេចមិនមកផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញនៅក្នុងរឿងសំណុំរឿងនេះវិញ ដោយសារតែលោកយល់ឃើញថាការផ្តល់សក្ខីកម្មនេះ ផ្តល់ការលំបាកដល់រូបលោក។ អង្គភាពគាំពារសាក្សី និង អ្នកជំនាញបានផ្តល់ការសម្របសម្រួលមួយចំនួនដើម្បីឱ្យការផ្តល់សក្ខីកម្មរបស់គាត់អាចនឹងប្រព្រឹត្តទៅបាន ដូចជា ការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ក្នុងន័យកាត់បន្ថយភាពលំបាករបស់លោក Vickery។ លោក Vickery បានឆ្លើយតបថាក្រៅពីក្តីបារម្ភផ្ទាល់ខ្លួនរបស់លោក លោកក៏បាន "ពិគ្រោះជាមួយនឹងមិត្តភក្តិរបស់លោកដែលជាមេធាវី មានបទពិសោធន៍លើបញ្ហាទាំងនេះ" ហើយលោក ត្រូវបានផ្តល់យោបល់ ថាលោកមិនគួរផ្តល់សក្ខីកម្មនោះទេ (*សូមមើល* ឯកសារ E408/4)។

៤. នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦ ក្រុមមេធាវីការពារក្តី អៀង សារី និង មាស មុត បានដាក់សំណើបន្ទាន់សម្ងាត់មួយ ស្នើសុំអង្គជំនុំជម្រះ ពិចារណាឡើងវិញលើសេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ស្នើសុំការអនុញ្ញាតដាក់សារណាពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មរបស់លោក Vickery (ឯកសារ E408/2/1)។ នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦ នេះដែរ សហព្រះរាជអាជ្ញា បានដាក់សំណើអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកឯកសារពាក់ព័ន្ធនឹងលោក Vickery និង លោក Henri Locard (2-TCE-90) (ឯកសារ E415/2)។ អង្គជំនុំជម្រះ បានចេញសេចក្តីសម្រេចផ្ទាល់មាត់ នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ ដោយកត់សម្គាល់ថា សំណើពាក់ព័ន្ធនឹង លោក Vickery លែងមានភាពចាំបាច់ទៀត

ហើយ (ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ ទំព័រ (ភាសាអង់គ្លេស) ៨២-៨៣ (សេចក្តីព្រាង))។

៥. នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦ អង្គជំនុំជម្រះ បានបង្គាប់ឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញទាក់ទងលោក Vickery និង ស្នើឱ្យលោក ជូនដំណឹងជាផ្លូវការដល់អង្គជំនុំជម្រះ ពីការសម្រេចចិត្តរបស់លោកថាតើលោកទទួល ឬ មិនទទួលធ្វើជាអ្នកជំនាញ និង សូមឱ្យលោកផ្តល់មូលហេតុអំពីការសម្រេចចិត្តកន្លងទៅរបស់លោកដែលថា មិនមកផ្តល់សក្ខីកម្ម។ ប្រសិនបើវាទាក់ទងនឹងមូលហេតុផ្នែកសុខភាព អង្គជំនុំជម្រះសាលាដំបូង ស្នើឱ្យគាត់បង្ហាញលិខិតពិនិត្យសុខភាព និង សួរគាត់ផងដែរថាតើគាត់ត្រូវការវិធានការអនុវត្តជាក់ស្តែងនានា ដើម្បីជួយកាត់បន្ថយការលំបាកនៃការផ្តល់សក្ខីកម្មរបស់គាត់ដែរ ឬ ទេ។

៦. នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦ មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំឱ្យទទួលយកអត្ថបទមួយ ដែលសរសេរដោយលោក Vickery អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E408/3)។

៧. នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦ អង្គភាពគាំពារសាក្សី និង អ្នកជំនាញ បានជូនដំណឹងដល់អង្គជំនុំជម្រះថា លោក Vickery បានបញ្ជាក់ថា លោកនឹងមិនមកផ្តល់សក្ខីកម្ម ហើយបន្ថែមថាព័ត៌មានដែលលោកបានផ្តល់ជូននោះគឺមានភាព"គ្រប់គ្រាន់ពេញលេញ"ហើយ។ លោក Vickery បានបង្ហាញថា លោក នឹងមិនផ្តល់លិខិតជូនដំណឹងជាផ្លូវការ ឬ ឯកសារពិនិត្យសុខភាពនោះទេ ហើយលោកក៏នឹងមិនពិចារណាលើការផ្តល់វិធានការអនុវត្តជាក់ស្តែងណាមួយផ្សេងទៀតនោះដែរ (*សូមមើល* ឯកសារ E408/4)។

៨. នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦ គ្រប់ភាគី ត្រូវបានជូនដំណឹងតាមរយៈសារអេឡិចត្រូនិក ពីអង្គជំនុំជម្រះ អំពីការបដិសេធមិនចូលធ្វើសក្ខីកម្មរបស់លោក Vickery ។ ជាមួយនោះផងដែរ រាល់ការឆ្លើយតប ឬ ការដាក់ឯកសារណាមួយដែលពាក់ព័ន្ធនឹងលោក Vickery ត្រូវបានផ្អាករហូតដល់មានការជូនដំណឹងបន្ថែម។ ដោយហេតុថា អ្នកជំនាញបានបញ្ជាក់បន្ថែមថាលោកនឹងមិនផ្តល់សក្ខីកម្មនៅក្នុងរឿងក្តីនេះ សំណើសុំដែលបានដាក់ជាបន្តបន្ទាប់ពាក់ព័ន្ធនឹងលោក Vickery នៅពេលនេះ មិនមានភាពចាំបាច់ទៀតឡើយ។ សំណើទាំងនោះគឺ (១) សំណើសុំជាសម្ងាត់ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលសហព្រះរាជអាជ្ញា

បានដាក់នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦ (ឯកសារ E415/2), (២) សំណើជាសម្ងាត់ ដែលក្រុមមេធាវីការពារក្ដី អៀង សារី និង មាស មុត បានដាក់នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦ សុំឱ្យពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ដែលបានបដិសេធមិនឱ្យដាក់សារណាពាក់ព័ន្ធនឹងសក្ខីកម្មរបស់លោក Vickery (ឯកសារ E408/2/1) និង (៣) សំណើសុំជាសម្ងាត់ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលមេធាវីការពារក្ដី ខៀវ សំផន បានដាក់នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦ (ឯកសារ E408/3)។